# ដំណាំត្រប់

## I. ស្ថានភាពទូទៅ

ត្រប់ជាដំណាំមួយដែលប្រជាជននៅលើពិភពលោកតែងតែបានស្គាល់ និង ប្រើប្រាស់ធ្វើជាម្ហូបអាហារប្រចាំថ្ងៃ យ៉ាងប្រជាប្រិយបំផុត ចាប់តាំងពីដើមសតវត្សទី១៦មកម្ល៉េះ។ នៅឆ្នាំ១៧៥៣ ក្រុមអ្នកវិទ្យាសាស្ត្រជាច្រើន បានកំណត់ប្រភេទ រុក្ខជាតិនេះនៅក្នុងក្រុមគ្រួសារ សូឡាណាសេ (Solanacear) លំដាប់ សូឡានូម Solanum។ ហើយមានឈ្មោះវិទ្យាសាស្ត្រហៅថាSolanum melonggnaL. ប៉ុន្តែវាក៏មានឈ្មោះផ្សេងៗទៀតជាច្រើនដូចជា នៅឆ្នាំ១៧៧៥ អ្នកប្រាជ្ញឈ្មោះ Forsskal បានអោយឈ្មោះ Solanum cagulans និងនៅឆ្នាំ ១៨៥២ អ្នកប្រាជ្ញ



និងដីឥដ្ឋ។ ប្រភេទដីដែលសមស្របសំរាប់ដំណាំនេះគឺដីឥដ្ឋល្បាយនិងដីល្បាយ



ឈ្មោះDun Dunal បានអោយឈ្មោះថាSolanum pressum។ នៅក្នុងប្រភេទដំណាំត្រប់មានច្រើន ប្រភេទដូចជា:

- ត្រប់ពុតញង: ឈ្មោះវិទ្យាសាស្ត្រហោថា Solanum torvum Swarte ឈ្មោះធម្មតាហោថា Bitter egg plant ។
- ត្រប់ស្រួយ ត្រប់ខារ ឬត្រប់ពងមាន់: ឈ្មោះវិទ្យាសាស្ត្រហៅថា Solanum macrocarpon ឈ្មោះធម្មតាអាចហៅថាBitter egg plant បានដែរ។
- ត្រប់ក្រាំងរមាស ឬត្រប់សណ្ដាយ: មានឈ្មោះវិទ្យាសាស្ត្រហៅថា Solanum melongena មានឈ្មោះធម្មតាហៅថា Egg plant ឬ ត្រប់ សណ្ដាយ និងត្រប់ក្រាំងរមាសដែលមានផ្លែសំប៉ែត ឬមូលតែពណ៌ប្រផេះឬបៃតង។ ជាទូទៅគេពិនិត្យឃើញមានចំនួន ២២ ប្រភេទនៃក្រុម Solanumនៅក្នុងប្រទេសឥណ្ឌា ។

តាមការស្រាវជ្រាវបានបង្ហាញថា ក្រុមនេះមានប្រភពកំណើតនៅតំបន់អាស៊ីដូចជា នៅប្រទេសចិន ឥណ្ឌា និងទ្វីបអាហ្វ្រិក។ ប៉ុន្តែក្រោយមករីករាយដាលដល់ទ្វីបអាមេរិក និងពេញពិភពលោក ជាពិសេសតំបន់សីតុណ្ហភាពក្ដៅ។ នៅប្រទេសកម្ពុជាយើង ត្រប់ជាប្រភេទបន្លែមួយយ៉ាងសាមញ្ញ ដែលប្រជាជនគ្រប់គ្នាតែងតែបរិភោគជាបន្លែក្នុងជីវភាពប្រចាំថ្ងៃ។ គេដាំដុះវាជាលក្ខណៈចំការធំៗតាមបណ្ដោយទន្លេមេគង្គនិងតំបន់ផ្សេងៗទៀតជាច្រើនតែដាំជាលក្ខណៈសួនបន្លែចំរុះ ។

ខ្សាច់ធ្វើអោយត្រប់ទទួលបានទិន្នផលខ្ពស់។ ប៉ុន្តែដីសំរាប់ដាំត្រប់គួរតែស្រទាប់ដាំដុះជ្រៅ និង pH ចាប់ពី៥,៥-៦,០ទើបទទួលបានល្អប្រសើរជាងដីដែលមានស្រទាប់ដាំដុះរាក់ pH ទាបជាង៥ឬខ្ពស់ជាង៨ វាតែងតែធ្វើអោយត្រប់ជួបប្រទះនូវបញ្ហាជំងឺកង្វះសារធាតុចិញ្ចឹមច្រើនលើផ្លែ ។

## III. បច្ចេកទេសដាំដុះ

### ១- ការជ្រើសរើសពូជ និងសំរិតសំរាំងកូន

- ការជ្រើសរើសពូជ: ដំណាំត្រប់ក៏ដូចជាដំណាំឯទៀតដែរ ការជ្រើសរើសត្រូវយកមកសំអាតជាមុន បន្ទាប់មកយកទៅដាក់ហាលថ្ងៃ។





## II. លក្ខខណ្ឌដី និងអាកាសធាតុ

### ១- លក្ខខណ្ឌអាកាសធាតុ

ដំណាំត្រប់គ្រប់ប្រភេទឆាប់ទទួលរងនូវអំពើប្រែប្រួលពី អាកាសធាតុជាពិសេសនៅពេលសីតុណ្ហភាពត្រជាក់ សំណើមបរិយាកាស ខ្ពស់វាធ្វើអោយឥទ្ធិពលនៃការបន្តពូជ ប្រដាប់បន្តពូជញីមិនទទួលយកលំអងផ្កាឈ្មោលក្នុងពេលវេលាដែលបង្កកំណើត ប៉ុន្តែសីតុណ្ហភាពត្រជាក់មធ្យមហើយរយៈពេលវែងក្នុងរដូវដាំដុះធ្វើឱ្យ ត្រប់ទទួលបានជោគជ័យ លើការងារកសិកម្ម ។ ចំពោះប្រភេទពូជដែលមានអាយុកាលលូតលាស់វែងអាចមានកំរិតធន់ទ្រាំ និងបន្សាំបានល្អក្នុងលក្ខខណ្ឌអាកាសធាតុប្រែប្រួលខ្លាំង។ នៅពេលយប់ត្រជាក់ហើយពេលថ្ងៃក្តៅរយៈពេលខ្លី (ថ្ងៃខ្លី) ធ្វើអោយត្រប់បាត់បង់ទិន្នផលច្រើន។ ប្រសិនបើសីតុណ្ហភាពមធ្យមប្រចាំថ្ងៃចន្លោះពី១៨-២៥$^{\circ}$C ធ្វើអោយការដុះលូតលាស់និងទិន្នផលខ្ពស់ជាទីបំផុតគឺដុះលូតលាស់លឿនផ្កាចេញស្រុះគ្នាល្អកំរិតបន្តពូជ និងការធំធាត់របស់ផ្លែបានល្អ។ នៅពេលសីតុណ្ហភាពឡើងខ្ពស់ពី៣០-៣៣ $^{\circ}$C និងមានខ្យល់បក់ខ្លាំងក្នុងអំឡុងពេល ត្រប់ចេញផ្កា វាធ្វើអោយមានឥទ្ធិពលអាក្រក់ដល់ផ្ការីក ហើយលទ្ធផលទិន្នន័យថយចុះក៏កាន់តែខ្លាំង ។ គ្រាប់ពូជដុះពន្លកបានល្អជាមធ្យម គឺ២៥ ។

### ២- អំពីលក្ខខណ្ឌដី

ត្រប់គឺជាប្រភេទដំណាំមួយដែលអាច ដុះលូតលាស់បានលើផ្ទៃដីស្ទើគ្រប់ ប្រភេទដូចជាប្រភេទដីខ្សាច់ស្រាល ខ្សាច់មធ្យម ខ្សាច់ធ្ងន់ ដីឥដ្ឋខ្សោយ ឥដ្ឋមធ្យម

ពូជមានសារៈសំខាន់បំផុតគឺសំដៅការលូតលាស់ និង អោយផលខ្ពស់។ ពូជត្រូវដឹងប្រភពត្រឹមត្រូវ ប្រភេទពូជបង្កាត់មានជំនាន់ Hybride $F_1$ ឬពូជបង្កាត់សេរី(OPV) ដែលហៅថា ពូជក្នុង ស្រុកមានអាយុកាលលូតលាស់ សមស្របនឹងតំបន់ដាំដុះព្រមទាំងពេញនិយមប្រើប្រាស់ ។ គ្រាប់ពូជមានសុខភាពល្អភាពសុទ្ធការកំណត់ប្រើដាក់លាក់។

- ការសាបកូន និងថែទាំកូនត្រប់: គ្រាប់ត្រប់តូចល្អិតសំប៉ែត សំបករឹងហើយក្រាស់ ជាទូទៅចំនួន ២៥០គ្រាប់អោយទំងន់១ ក្រាម។ ដើម្បីដាំលើផ្ទៃ ដី១ ហ.តគេត្រូវប្រើគ្រាប់ពូជចំនួន ៣៧៥-៥០០ក្រាម។ មុននឹងសាបគ្រាប់ពូជ





រយៈពេល ១-២ ម៉ោងក្រោយមកទៀតយកទៅត្រាំទឹកក្តៅឧណ្ហៗ រយៈពេល១៥-២០នាទីទើប ត្រាំទឹកត្រជាក់ធម្មតា មួយយប់ក្រោយមកយកទៅផ្អាប់ពីរយប់ នៅពេលគ្រាប់ ត្រប់ដុះពន្លកសៗដំបូងអាចយកទៅសាបឬដាក់ក្នុងកន្ទោងក៏បាន។ របៀបសាប ឬ បណ្តុះត្រប់មានច្រើនវិធីដូចខាងក្រោមនេះ

វិធីសាប និងថ្នាលធម្មតា: ដំបូងត្រូវរកទីតាំងថ្នាលសាបគឺស្រឡះ ដីទួល ស្រស់ទឹក មានជីជាតិល្អ បន្ទាប់មកត្រូវកាប់ហាលដីអោយ ស្វួតទើបលើករងអោយបានត្រឹមត្រូវ ដីលើរងគឺអោយម៉ដ្ឋល្មមកៀរអោយស្មើ (គួរធ្វើដំបូលប្រក់ពេលមេឃភ្លៀង) ទើបយកជីប្រភេទ ស៊ុបពែផូស្វាត មកបាចពីលោកចំនួន ១៥០ ក្រាម សម្រាប់ផ្ទៃថ្នាល ១០ម២ ឬជី ១៥.១៥.១៥ ចំនួន ២០០ក្រាម បន្ទាប់មករាស់លុបជីទាំងនោះអោយកប់ជ្រៅទៅក្នុងដី។ ការសាបគ្រាប់ពូជត្រូវពោយកំទេចចំបើងចិញ្ច្រាំខ្លីៗពីលើតាមក្រោយ ដើម្បីការពារសំណើមដី បន្ទាប់មកស្រោចទឹកអោយជោគហើយស្រោចសូលុយស្យុងថ្នាំផ្សិតដូចជា Mancozeb ការពារជំងឺរលួយកូន ឈ្មោះDamping off នៅពេលវាដុះថ្មីៗ។ ការស្រោចទឹកដកស្មៅនិងជីបំប៉នត្រូវធ្វើឡើងជាប្រចាំ ដើម្បីអោយកូនដំណាំលូតលាស់ល្អ ក្រោយពីសាបរយៈពេល ៣-៤អាទិត្យអាចដកយក ទៅដាំបាន ។

*ការសាបនឹងថ្នាលដីខ្សាច់៖*ដំបូងត្រូវធ្វើឡាំងឬកេសដែលមានទទឹង០,៥ម បណ្តោយ១ម ជំរៅ៥សម បាតកេសត្រូវមានរន្ធតូចៗ យកដីខ្សាច់ម៉ដ្ឋដុតសំលាប់ មេរោគជាមុនហើយទុកអោយត្រជាក់ ទើបចាក់ចូល ក្នុងកេសអោយពេញ ស្រោច ទឹកអោយជោគបន្ទាប់មកយកគ្រាប់ដែលដុះពន្លកសៗ ទៅសាបតាមចង្អូរជំរៅ ១សម ចន្លោះចង្អូរ៥សម ក្រោយសាបហើយត្រូវលប់ដីខ្សាច់នោះពីលើអោយជិត គ្របចំបើង ស្ងួតពីលើហើយស្រោចទឹកអោយជោគព្រឹក ល្ងាច រយៈពេល ២-៣ថ្ងៃ អាចបកចំបើងនោះចេញ គឺពេលគ្រាប់ដុះទូលដីខ្សាច់ចេញមក។ ក្រោយពីវាដុះមាន សន្លឹកកំណើតដំបូង មានអាយុ ៧-១០ថ្ងៃ អាចដកកូនពីកេសដីខ្សាច់ទៅស្ទូងលើថ្នាល ឬកន្ទោងដែលបានបំពេញដោយដីមានជីកំប៉ុស្តិ និងអង្កាម ។





ការថៃទាំស្រោចទឹកស្រោចជីអាចធ្វើឡើងដូចគ្នានឹងការសាបថ្នាលធម្មតាដែរតែការសាបរបៀបនេះ បើគ្រាប់ពូជចំនួនតិចអាចដាំបានផ្ទៃដីធំ ហើយកូនគ្រប់ឆាប់បានយកទៅដាំ គឺរយៈពេលតែបីអាទិត្យប៉ុណ្ណោះ ។

**២- រដូវកាលដាំដុះ**

គ្រប់ជាប្រភេទដំណាំមួយដែលលូតលាស់ពេញ១ឆ្នាំដោយមិនប្រកាន់រដូវក៏ប៉ុន្តែនៅពេលសីតុណ្ហភាពឡើងខ្ពស់ ធ្វើអោយត្រប់ បន្ថយការចេញផ្កា ឬពេលសំណើមដីមិនគ្រប់គ្រាន់ធ្វើអោយត្រប់ផ្លែមិនបានវែងហើយមានរស់ជាតិល្វីងខារ នៅប្រទេសកម្ពុជាយើង គេបែងចែករដូវដាំដុះជាពីរ គឺរដូវប្រាំង និងរដូវវស្សា។ នៅតំបន់ទំនាបទន្លេមេគង្គ និងជុំវិញទន្លេសាបការដាំដុះចាប់ផ្តើមពីរដូវទឹកសំរក នៅខែតុលា វិច្ឆិកា ដល់ខែកក្កដា និងសីហានៅតំបន់ខ្ពង់រាប និងភ្នំ គឺពីខែឧសភាដល់ ខែវិច្ឆិកា ដែលភាគច្រើនស្រោចស្រពដោយទឹកភ្លៀង។

**៣- ការរៀបចំដី**

ការរៀបចំដីមានសារៈសំខាន់បំផុតសំរាប់ការដាំ និងដុះលូតលាស់ ។ការភ្ជួរអោយជ្រៅរាស់បំបែកដីអោយម៉ដ្ឋនិងច្រើនលើកគឺ រឹតតែធ្វើអោយដីធូរមានបន្ទុកខ្យល់គ្រប់គ្រាន់ គឺជួយសំរួលដល់ការដុះលូតលាស់នូវប្រព័ន្ធឬសជ្រាបទឹកបានរហ័ស សំរួលអោយការស្រូបយកជីជាតិបានល្អ។ ការរៀបចំដីអាចធ្វើឡើងទៅតាមរបៀបផ្សេងៗគ្នា ដូចជាកាប់នឹង ចប ភ្ជួរនង្គ័ល គោយន្ត ឬត្រាក់ទ័រ ទៅតាមលទ្ធភាព និងទំហំ។

### ៤- របៀបដាំដុះ

បន្ទាប់ពីលើករងហើយត្រូវកាប់ជារណ្តៅតាមបណ្តោយរង ឬ ថ្នាលដាំមួយជួរគឺចន្លោះជួរ ១០០-១២០សម ចន្លោះគុម្ព ៧០-៨០សម មួយគុម្ព មួយ ដើម។ ជំរៅរណ្តៅដែលកាប់គឺ ៨-១០សម ក្នុងរកណីកូនគ្រាប់សាបលើថ្នាល ផ្កាល់គេត្រូវស្រោចទឹកកូនគ្រាប់អោយជោគរយៈពេល២០-៣០នាទីមុនដកដើម្បីបន្ធូរការដាច់ឬស ។ កូនគ្រាប់ត្រូវដកពីពេលព្រឹក បន្ទាប់មកយកវាទៅដាក់ ក្នុងឧបករណ៍ ដូចជា កញ្ជើ ល្អី កញ្ជេ ។ល។ ហើយស្រោចទឹកអោយជោគរក្សាទុកនៅក្រោមម្លប់ ធ្វើអោយកូនគ្រាប់មានសភាពរឹងមាំធន់កំដៅថ្ងៃក្រោយមកទើបយកទៅដាំនៅពេលរសៀល ចាប់ពីម៉ោង២រហូតដល់ ពេលល្ងាចត្រជាក់ក្រោយពីដាំភ្លាមត្រូវស្រោចទឹក អោយជោគតាមរណ្តៅនីមួយៗ ។





ផ្ទៃដី ។ ដំបូងត្រូវរាស់ប្រមូលនូវស្មៅ កាកសំណល់ដំណាំចាស់ ដុត ឬ យកចេញពីចំការបន្ទាប់មកភ្ជួរហាលដីរយៈពេល ៥-៧ថ្ងៃ អោយស្មៅងាប់និងផ្តាច់ជីវិតពពួកសត្វល្អិត ចង្រៃផ្សេងៗ នៅក្នុងដីក្រោយមកទើបរាស់បំបែកដីអោយម៉ដ្ឋនិងកៀរអោយស្មើ។ ដើម្បីលើករងដាំបានត្រូវភ្ជួររាស់ដីអោយបាន ៣-៤លើក។ ការដាំតាមរបៀបកសិករគេមិនលើករងឡើយ តែដើម្បីអោយងាយស្រួលស្រោចគេលើករង។ ការលើករងមានសារៈសំខាន់បំផុត ដូចជានៅរដូវវស្សា ការលើករងអោយមានកំពស់ ខ្ពស់ធ្វើអោយទឹកហូរចេញពីចំការបានរហ័ស។ នៅរដូវប្រាំងករណីរងខ្ពស់ងាយបញ្ជូលទឹក។ រងឬថ្នាលសំរាប់ដាំគ្រាប់គឺមានទទឹង ១០០សម កំពស់ ២០-២៥សម បណ្តោយតាមលទ្ធភាព ឬសភាព របស់ដី។



## ៦- ការប្រើប្រាស់ជី

គ្រប់ត្រូវការសារធាតុចិញ្ចឹមមុខ គឺ វាត្រូវការជីដែលមានជីជាតិច្រើន ដែលជាសមាសធាតុសំរាប់ផ្តល់ដល់ការលូតលាស់ និងមានទិន្នផលខ្ពស់ ។ ជីធម្មជាតិដូចជាកំប៉ុស្តផ្សំ លាមកសត្វគ្រប់ប្រភេទជីស្រស់ ឬជីបៃតងសុទ្ធសឹងជាសមាសធាតុ ដែលបណ្តោលអោយលូតលាស់ លឿន និងទិន្នផលខ្ពស់។ ជីអាចម៍មាន់គេប្រើកំរិតពី ៨-១០តោន/ហាត ជីលាមកគោ ក្របីចំនួនពី ១៥-២០តោន/ហាត ជាពិសេសគឺដាក់នៅ ពេលដាំដែលហៅថាជីទ្រាប់បាត។ ដំណាំនេះត្រូវការសារធាតុសំខាន់ៗ ដូចជា N, P, K, Ca, S, Fe និងB ។ កាលណាកង្វះសារធាតុទាំងនេះអាចលេចចេញនូវសញ្ញាដូចតទៅ

- កង្វះធាតុអាសូត(N) ធ្វើអោយដើមមែកឈរត្រង់ ស្លឹកខៀវស្រអាប់ ហើយគឿមិនបែកមែក ។

- កង្វះធាតុផូស្វ័រ (P) ស្លឹកប្រផេះស្រអាប់ហើយធ្វើអោយស្លឹកឆាប់ប្រែពណ៌ទៅជាលឿងទុំជ្រុលមុនអាយុដើមមែកទន់មិនរឹងមាំ ។

- កង្វះធាតុប៉ូតាស្យូម (K) និងដែកFe: ធ្វើអោយពណ៌បៃតងនៃត្រួយខ្ចីៗរបស់ស្លឹកក្លាយទៅជាពណ៌លឿងព្រមទាំងលូតលាស់មិន ពេញលេញឆាប់ទទួលរង ជំងឺផ្សេងៗ ពិសេសជំងឺផ្សិតលើស្លឹក ។



## ៥- ការស្រោចស្រព

ទឹកជាកត្តាសំខាន់សំរាប់បំលែងសារធាតុចិញ្ចឹម គឺធ្វើអោយជីជាតិទាំងឡាយនៅក្នុងដីរលាយហើយអាចអោយដំណាំស្រូបយកបានទៅចិញ្ចឹមសរីរាង្គ។ គ្រប់ជាប្រភេទដំណាំមួយដែលត្រូវការទឹកជាប្រចាំ ដើម្បីរក្សាសំណើមដី ដូចនេះចាប់ពីពេលដាំក្លាមត្រូវតែស្រោចទឹកជាបន្ទាន់ ហើយបន្តស្រោចជាធម្មតាមួយថ្ងៃ ១-២លើកព្រឹក-ល្ងាច ប៉ុន្តែនៅពេលគ្រប់ចាប់ផ្តើមចេញផ្ការហូតដល់ពេលប្រមូលផលវាត្រូវការទឹកច្រើនជាងពេលដាំ ។ក្នុងដំណាក់កាលនេះគេអាចបញ្ចូលដោយម៉ាស៊ីនទៅតាមចន្លោះរងក៏បានហើយបាញ់អោយជោគក៏បានធ្វើយ៉ាងណាអោយដីមានសំណើមកាន់តែខ្លាំងក្នុងដំណាក់កាលនេះជាពិសេសនៅរដូវប្រាំង



### ៧- ការកំចាត់ស្មៅ

ការកំចាត់ស្មៅ គឺគេចាប់ផ្ដើមអនុវត្តតាំងពីចាប់ផ្ដើមភ្ជួរដីមកដោយរាស់ប្រមូលដុតចោលទើបភ្ជួរដី ។ ការដាំដុះលក្ខណៈទីផ្សារធំៗមុនរាស់យកស្មៅចេញ គេប្រើថ្នាំសំលាប់ស្មៅឈ្មោះGlyphosate ឬ Glycine ៤៨ ១ហាតផ្ទៃដីប្រើ ២,៥លីត្រ ។ វិធីប្រើគឺកំរិត ៦៥-៧០ CC លាយទឹក ២០លីត្រ បាញ់លើផ្ទៃដី២០០ម² ក្រោយ ពីបាញ់រយៈពេល៧ថ្ងៃ ទើបចាប់លផ្ដើមរាស់ប្រមូលផលយកស្មៅចេញហើយភ្ជួរ ហាលដី។វិធីសាស្ត្រធ្វើដោយចបគឺក្រោយដាំ២អាទិត្យគេត្រូវជ្រំជ្រោយ ដីឱ្យផុស ល្អហាលដី២ ថ្ងៃទើបពូនរងឡើងវិញ ដើម្បីអោយស្មៅចង្រៃងាប់។ លើកទី២ គេអាចជំរះយកស្មៅចេញតែមិនជ្រំជ្រោយដីឡើយ ។

### IV. អំពីជំងឺ និងវិធានការការពារ

គ្រប់ជាប្រភេទដំណាំមួយដែលទទួលរង ការបំផ្លាញពីជំងឺផ្សិតតូច ដើមស្លឹក ឬស និងផ្លែ ។

ជំងឺរលួយគល់កូនគ្រប់: ឈ្មោះ (Damping off Pythium SPP. Rhizontonia Spp) តាមធម្មតាជំងឺផ្សិតតែងតែកើតឡើងដោយលក្ខខណ្ឌ អាកាសធាតុនិងបណ្ដាលមកពីកត្តាសំណើមនៃដី។ប្រភេទជំងឺរលួយគល់កូនគ្រប់ឈ្មោះ DamPing off នេះគឺបំផ្លាញ កូនគ្រប់ទើបនឹងដុះរហូតដល់កូនគ្រប់មាន សន្លឹកពិតលក្ខណៈពិសេសរបស់វាគឺ បណ្ដាលមកពីដីដែលមានមេរោគ ។

**វិធានការការពារ**

ត្រូវបាចកំបោរសចំនួន ២៥០-៣៥០គក្រ/ហាត ហើយភ្ជួរលុបរយៈពេលពីរ



ដំណាំនេះគេប្រើជីមានច្រើនដំណាក់កាលដូចជា៖មុនពេលដាំ (ទ្រាប់បាត) ប្រើជី ១៥,១៥,១៥ ចំនួន ២០០គក្រ/ហាត ក្រោយដាំ រយៈពេល ៧-១០ថ្ងៃ ប្រើជីអ៊ុយរ៉េ ៤៦% ចំនួន ៦៥គក្រ/ហាតដោយលាយទឹកស្រោច ឬដាក់ក្បែរគុម្ព ហើយស្រោចទឹកក៏បាន ។ រយៈពេលបីអាទិត្យក្រោយដាំគេដាក់ជីបំប៉នប្រភេទ ១៥,១៥,១៥ ចំនួន ២០០គក្រ/ហាតដោយដាក់តាមចន្លោះគុម្ព ហើយលុបដីអោយជិតស្រោចទឹកអោយជោគ។ លើកចុងក្រោយគឺដាក់ជីប្រភេទអ៊ុយរ៉េចំនួន ៨៤គក្រ លាយជាមួយ ជីផូស្វាត ($P_2O_5$20%) ចំនួន១០០គក្រដើម្បីដាក់លើកផ្ទៃដី ១ហាតនៅពេលគ្រប់ ចាប់ផ្ដើម ប្រមូលផលលើកទីមួយមានរយៈពេល ៦៥-៧០ថ្ងៃ ក្រោយដាំ ។



- សប្តាហ៍ ទើបរៀបចំដីដាំបាញ់ថ្នាំផ្សិតដូចជា Mancozeb Manev ឬ Captan មួយអាទិត្យម្តងៗ ចាប់ពីសាបរហូតដល់គ្រាប់ចេញផ្កា និង ផ្លែ ។

## V. អំពីសត្វល្អិត

សត្វល្អិតដែលបំផ្លាញដំណាំត្រប់មានពីរក្រុមធំៗ ក្រុមចោះ និងស៊ី បំផ្លាញព្រមទាំងក្រុមជញ្ជក់យករុក្ខរស ។ ក្រុមស៊ីបំផ្លាញ ៖ ដង្កូវស៊ីរូងផ្លែ ដើម ស្លឹក ដូចជា: ដង្កូវស៊ីរូងផ្លែ និងដើម ឈ្មោះEgg Plant Fruit and Shoot bore ដែលមានឈ្មោះវិទ្យាសាស្ត្រនៅក្នុងគ្រួសារ Leucinodes Orbonalis Lepidoptera IMdab; Pyraliden លក្ខណៈនៃការបំផ្លាញមេអំបៅតែងពងដាក់ស្លឹកខាងក្រោមរាយៗ ជាក្រុមខ្លះទៀតពងដាក់លើផ្កា និង ដើមក្រោយមកពងវាញាស់ហើយចោះចូលទៅក្នុងដើមផ្នែកខ្ចីនៃត្រួយ ឬ ក្តឹបខ្ចីធ្វើអោយត្រួយនៃដំណាំគ្រប់ស្រពោន ផ្លែគ្រប់ស្អុយមិនអាចលូតលាស់បាន ជាពិសេសវាបង្កកំណើតនៅលើគ្រប់ដំណាំអំបូរ សូឡាណាសេ ធ្វើអោយវាមានលទ្ធភាពពង្រីកប្រជាករបានយ៉ាងលឿនក្នុងលក្ខខណ្ឌអាកាសធាតុក្តៅ។

ដើម្បីការពារទៅនឹងកត្តាចង្រៃ បែបនេះគេត្រូវអនុវត្តតាមវិធីសាស្ត្រច្រើនយ៉ាងដូចជា ជ្រើសរើសពូជធន់ទ្រាំល្អ រៀបចំដីឱ្យត្រឹមត្រូវ ផ្លាស់ប្តូរមុខដំណាំ ជ្រើសរើសរដូវដាំអោយមានចន្លោះជួរនិងគុម្ពអោយបានត្រឹមត្រូវកាត់រំលោះស្លឹកចោលខ្លះសំអាតស្មៅក្នុងចំការព្រមទាំងវិធានការគីមីរួមផ្សំពេលសត្វល្អិតទើបនឹងកើត ។

## VI. ការប្រមូលផល

គ្រាប់អាចប្រមូលផលបានក្រោយពី ដាំរយៈពេលខុសៗគ្នាទៅតាម



ប្រភេទ របស់គ្រាប់ និងប្រភេទរបស់ពូជ។

- ប្រភេទគ្រាប់ផ្លែខ្ចីដូចជាគ្រាប់ពងមាន់ គ្រាប់ក្រាំងរមាសនិងគ្រាប់សណ្តាយ



ផ្លែខ្ចីវាគឺន្លោះពី ៧០-៧៥ថ្ងៃ ហើយការប្រមូលផលអាច ច្រើនលើកអាស្រ័យទៅលើការថែទាំជាពិសេសគឺការកាត់ស្លឹកចាស់ចោល ដាក់ជីបន្ថែម និងស្រោចទឹក ។ ចំពោះទិន្នផលជាមធ្យមគ្រាប់ក្រាំង រមាសគឺ ១១-១៣តោន/ហាត គ្រាប់ពងមាន់ចន្លោះពី ៨-១០តោន/ហាត រីឯគ្រាប់សណ្តាយផ្លែខ្ចីចន្លោះពី ៧-៩តោន/ហាត។ ប្រភេទគ្រាប់សណ្តាយផ្លែវែង អាចមានអាយុប្រហែលគ្នានឹងគ្រាប់ខាងលើដែរ អាស្រ័យទៅតាមប្រភេទពូជពូជទំនើបចន្លោះពី៦៥-៧៥ថ្ងៃ។ ពូជក្នុងស្រុកចន្លោះពី៧៥-៨០តោនថ្ងៃ រីឯទិន្នផលចន្លោះពី ៨-១៣តោន/ហាត។ គ្រាប់អាចប្រមូលផលបានច្រើនសារអាស្រ័យ លើការថែទាំ និងការកាត់ស្លឹកចាស់ៗ ចោលនៅពេលវាបន្ថយផ្កា។ ដើម្បីអោយផ្លែគ្រាប់រក្សាបាននូវសោភ័ណភាពល្អ និងគុណភាព គេតែធ្វើការប្រមូលផលពេលព្រឹកព្រលឹមល្ងាចត្រជាក់ក្រោយពីស្រោចទឹកហើយ ។ បេះហើយត្រូវយកទៅផ្សើមទឹក ជាចំហាយបន្តិចៗទើបរៀបចំទុក ដាក់ក្នុងឧបករណ៍ដឹកជញ្ជូន ។